# គ្រូបង្រៀនស្រុកស្រែ

**ភាគទី៤**

**(៩.មធ្យោបាយផ្សេងៗ)**

*កក្កដាបានកន្ទង់ផុតៗ សីហាចូលដាង១៩ថ្ងៃ...ៗ បដាចាស់ខ្លះដែលបានចងសន្ទឹងទទឹងផ្លូវនៅទីប្រជុំជនបានត្រូវបណ្ដាច់ៗ ខ្លះទៀតបានត្រូវខ្យល់បកហែក...ៗ បដាថ្មីបានចងជំនួសៗ នៅផ្លូវបំបែកទៅពាម ទៅកំពង់ ទៅភ្នំពេញ ខាងត្បូងម៉ាស៊ីនស្រូវមុខផ្ទះបងហម ចំងាយប្រហែល៥០០ម៉ែត្រ បដាថ្មីមួយ បានចងសន្ទឹងមានលំអដោយមនុស្សពាក់ខ្លួនក្ដួរនង្គ័លទឹមមនុស្សពីរនាក់ ហើយនៅខាងមុខនង្គ័លទឹមមនុស្សនោះមានរូបមនុស្សស្លួចខ្ពស់ពាក់មុខប្រមោយដំរីៗ បដាថ្មីចំលែកខុសពីបដាមុន បានចាប់ភ្នែកមនុស្សដោយទៅកកកុញមើលៗ អ្នកជិះឡានទៅភ្នំពេញក៏បានឃើញដែរៗ បដាថ្មីនេះបានឲ្យអ្នកដំណើរ និងអ្នកភូមិមានយោបល់ខុសៗគ្នាៗ ខ្លះថាអញប្រាប់យូរហើយ ពួកវានេះហើយ ដែលជាអ្នកប្រឆាំងដុតក្បាលបញ្ជី និងត្រាមេឃុំៗ ខ្លះថាបើមិនធ្វើដូច្នេះខ្លះ ធ្វើដូចម្ដេចបោសសំអាតអាណានិគមបានៗ ខ្លះថាពួកអាដំរីនេះហើយ ដែលឲ្យតំណាងរាស្ត្របានអភ័យឯកសិទ្ធិធំពេកៗ*

*ទន្ទឹមនឹងបដា ខិតប័ណ្ណជាច្រើនម៉ឺនសែនលាន បានបាចសាចរាយពាសវាលពាសភូមិ ខិត្តប័ណ្ណខ្លះស្រែកថា មានតែប្រជាជនអាចដោះទុក្ខប្រជាជនបានៗ ខ្លះទៀតបានលាតត្រដាងបញ្ជាក់ថានារីឈ្មោះនេះ ឈ្មោះនោះជានារីខ្វាឃ្លោកមិនមែនជានារីក្លាហានទេៗ ខ្លះបានស្រែកថារួបរួមសាមគ្គីប្រជាជនគ្រប់ជាន់ថ្នាក់ ប្ដេជ្ញាការពារសន្តិភាព ឯករាជ្យ ប្រជាធិបតេយ្យ...ៗ*

*ពេលខ្លះនៅតែហូរធ្ងង...ៗ ១១ កញ្ញាកាន់តែខិតមកជិតៗ ចំបាំងបដាខិតប័ណ្ណមិនស្កប់ស្កល់ មិនគ្រប់គ្រាន់តាមបំណងទេៗ នៅត្រង់ផ្លូវបំបែកទៅពាមទៅកំពង់ ត្រង់ទីប្រជុំជនច្រើននេះ សកម្មភាពសង្គម និងបក្សនយោបាយរិតប្រញឹកកំរិតប្រញាប់ៗ បន្តិចមេក្រូស្រែកប្រាប់ថា អ្នកកំពង់មកឃោសនាៗ បន្តិចខិតប័ណ្ណព្រាចតាមដងផ្លូវ អំពាវនាវអ្នកស្រុកឲ្យទៅស្ដាប់អ្នកភ្នំពេញៗ បន្តិចក្បួនឡានទាហានស៊ីវិលតូចធំទៅពាមៗ បន្តិចមេឃុំ ប៉ូលីស មេកងភូមិឃុំបានទៅនិមន្តលោកសង្ឃ និងហៅប្រជាជនឲ្យមកសាលាស្រុក បន្តិចក្បួនឡានធំពេញដោយ*

*អត្ថបទដោយ៖ មាស សុភាព*

សិស្សហួសទៅកំពង់...។ នៅស្រុកម៉ាស៊ីនស្រូវត្រូវការប្រជាជនមានស្មើរពល់ថ្ងៃ ជូនទៅសាលាស្រុក ជូននៅថ្នល់បំបែក ជូននៅទីវាលមុខម៉ាស៊ីនស្រូវធំ...។ ឃោសនាម្តងៗ សុទ្ធតែមានអ្នកបន្ទរ និងអ្នកប្រឆាំង។ អ្នកស្របច្រើនបានលាន់មាត់ថា: នេះបានចំជាពិរោះ ចំជាចេះនិយាយ ចំជាគិតប្រយោជន៍រួមមែន។ អញថាយូរហើយ ឥលូវដូចអញស្មានមែន...។

ឯអ្នកប្រឆាំងក៏មិនមែនបើកមាត់ដែរ។ ខ្លះខំផ្ទៀងស្តាប់កត់ទុក ហើយត្មិះតេះដៀលខ្លះប្រទេឡាតខឹងរអ៊ូប្រាប់អ្នកនៅបៀតខាងថា:....ឃើញទេវានិយាយអួតតែពីហ្សឺណែវ។ វាថាការបោះឆ្នោតនេះសម្រេចមកពីហ្សឺណែវ មិនមែនបារាំងឲ្យបោះទេ...។ មើលវាថាកិច្ចព្រមព្រៀងយោធាខ្មែរអាមេរិកកាំងប្រឆាំងបំផ្លាញអព្យាក្រឹត្យ ឃើញទេ វាចោទរដ្ឋាភិបាល...។ អញផ្តិចមេដៃប្តឹងចាប់ដាក់គុកហើយ...។

មានខ្លះទៀតមិនខ្ជីស្តាប់ មិនខ្ជីញុំ។ ពួកនេះច្រើនជាប់មាត់នឹងឪទិន។ គេដាក់មួយចានហើយមួយចានទៀត អស់ស្រេះមួយហើយស្រេះមួយទៀត។ អស់ចិត្តដល់ព្រះអង្គគេកាលណា គេបញ្ចេញឥទ្ធិពលសាហាវគេភ្វាម។ គេឈ្លោះ គេប្រកែក គេដេញ។ គេឡូឡាស្រែកគំហកទៅឲ្យអ្នកឃោសនាថា អញថាវាយចោលម្រ៉ាយឥឡូវ...វាណាមួយនៅឈរត្រង់ណាអញចោលបែកក្បាលឥឡូវ។ គេវាយប៉ោត គេទះក្តិត គេស្រែកជេរ គេគប់ គេចោល គេឡើងបណ្តាច់បដា គេដេញវាយ...។ ប្រៀប្រឆាំងតាមកំលាំងឪទិនមួយស្រេះពីរស្រេះបានយ៉ាងស្រួល គ្មានភ្នាក់ងាររក្សារបៀបរៀបរយហាមប្រាមឡើយ។

ហើយធម្មតាគេឃើញអ្នកជារត់ចោលអ្នកស្រវឹង គេឃើញអ្នកឪទិន និងអ្នកប៉ោត បណ្តេញបង្អាក់អ្នកមេក្រូ ឲ្យឈប់និយាយ ដោយសាររោងរត់ទៅលំនៅវិញ។ អ្នកមេក្រូដកថយគ្រវីក្បាល។ ខ្លះជិះឡានរត់ភ្នែកនៅកញ្ជឹងក។ ខ្លះទៀតអស់សំណើចពោលពាក្យថា ស្រាខ្លាំងជាងមនុស្ស មែនចេះឲ្យមនុស្ស ជាលែងទៅឆ្កួត លែងដឹងការខុសត្រូវ...។

ចំណែកអ្នកភូមិធម្មតា គ្មានបក្សពួកច្រើនតែរអ៊ូរោលអាលថា: បើវាមិនស្តាប់ទេ ចុះហេតុអ្វីក៏វានៅសំដែងថោកទាបឆ្កួតដូចនេះ...វាមិនខ្មាស់គណ:អន្តរជាតិទេ រឺបើឃើញយើងស្រវឹងឆ្កួតដូចនេះ ក្នុងពេលប្រលងប្រណាំងកសាងជាតិ...។

**(សូមរង់ចាំតាមដាន រឿង គ្រូបង្រៀនស្រុកស្រែ ភាគទី៩ នៅសប្តាហ៍ក្រោយ)**

អត្ថបទដោយ៖ មាស សុភាព